ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៦៤៤៧ អយក.ចរ

**សូមគោរពជូន**
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**កម្មវត្ថុ ៖** សំណើសុំជួយដោះស្រាយបញ្ហាប្រឈមនៃការអនុវត្តថវិការបស់សាលារៀនសាធារណៈចាប់ពីឆ្នាំ២០១៩ និងឆ្នាំបន្តបន្ទាប់ខាងមុខ។

**យោង ៖** លិខិតលេខ១០០៤៣ សហវ.អថ ចុះថ្ងៃព្រហស្បតិ៍ ១រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា៖ កន្លងមក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តែងតែចូលរួមសហការជួយសម្របសម្រួលយន្តការនិងនីតិវិធីហិរញ្ញវត្ថុក្នុងការដោះស្រាយបញ្ហាប្រឈមបានជាច្រើន។ ទោះជាយ៉ាងនេះក្តី ក៏នៅមានបញ្ហាប្រឈមខ្លះនៅសេសសល់ក្នុងឆ្នាំចាស់និងកើតថ្មីមិនទាន់បានដោះស្រាយចប់សព្វគ្រប់នៅឡើយ ជាហេតុនឹងធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តថវិកាឆ្នាំ២០១៩និងបណ្តាឆ្នាំខាងមុខ។ ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡា ចាំបាច់ត្រូវស្នើសុំការអនុញ្ញាតជាគោលការណ៍ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជួយដោះស្រាយនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

**១**-អនុញ្ញាតជាគោលការណ៍ឲ្យក្រសួងអប់រំ យុវជន និងកីឡា ដោយបង្វែរថវិកាដំណើរការសាលារៀន (SOB) ឆ្នាំ២០១៩ ចូលគណនីធនាគារសាលារៀនសាធារណៈទូទាំងប្រទេសចំនួនពីរលើកក្នុងមួយឆ្នាំគឺ៖

**-លើកទី១៖** នៅដើមខែ មករា ឆ្នាំ២០១៩

**-លើកទី២៖** នៅដើមខែ មិថុនា ឆ្នាំ២០១៩ ។ ដូចនេះ ដើម្បីឲ្យស្របជាមួយនឹងគោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ ដែលបានឯកភាពតាមរយៈលិខិតលេខ១០០៤៣ សហវ.អថ ចុះថ្ងៃព្រហស្បតិ៍ ១រោច ខែ អស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**២**-អនុញ្ញាតជាគោលការណ៍ ឲ្យក្រសួងអប់រំ យុវជន និងកីឡា បានបង្វែរថវិកាចំនួន៤ ០៥០ ០០០រៀល/សាលារៀន ចូលគណនីធនាគារសាលារៀននៅដើមខែមករា ឆ្នាំ២០១៩ ដើម្បីបង្កលក្ខណៈងាយស្រួលដល់សាលារៀនសាធារណៈ ក្នុងការរៀបចំដកសាច់ប្រាក់ផ្ទាល់សម្រាប់ទិញបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា គឺកុំព្យូទ័រមួយគ្រឿងនិងម៉ាស៊ីនព្រីនធ័រមួយគ្រឿង ដោយសាលារៀនសាមី ។ ទន្ទឹមនឹងនេះ ក្រសួងអប់រំ យុវជន និងកីឡា នឹងរៀបចំលិខិតណែនាំ ស្តីពីការកំណត់ស្តង់ដាអប្បបរមានៃលក្ខណៈបច្ចេកទេសរបស់កុំព្យូទ័រ និងម៉ាស៊ីនព្រីនធ័រ ជូនដល់សាលារៀនសាធារណៈទូទាំងប្រទេស។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

៣-អនុញ្ញាតជាគោលការណ៍ ឲ្យក្រសួងអប់រំ យុវជន និងកីឡា បានបង្វែរថវិកាអាហារូបករណ៍ ចូលគណនីធនាគារសាលារៀនដោយផ្ទាល់ ដើម្បីឧបត្ថម្ភជូនសិស្សក្រីក្រជួបការលំបាកនៅបឋមសិក្សានិងមធ្យមសិក្សាចំណេះទូទៅ ដែលស្ថិតក្នុងអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលកម្ពុជា ដោយអនុវត្តតាមលំនាំប្រកាសអន្តរក្រសួងលេខ៣៦៦ សហវ.ប្រក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការអនុវត្តថវិកាសម្រាប់ដំណើរការសាលារៀនសាធារណៈ ក្នុងគោលបំណងបង្កលក្ខណៈងាយស្រួលដល់ការបើកសាច់ប្រាក់ឲ្យទាន់ពេលវេលា។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យលទ្ធភាពនិងជួយដោះស្រាយបញ្ហាប្រឈម ជូនក្រសួងអប់រំ យុវជន និងកីឡា ឲ្យទាន់ពេលវេលា ដើម្បីសម្រួលការអនុវត្តថវិកាក្នុងឆ្នាំ២០១៩ និងបណ្តាឆ្នាំខាងមុខ ឲ្យប្រព្រឹត្តទៅប្រកបដោយនិរន្តរភាព ដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

ថ្ងៃ ៤ ៖ ១០ កើត ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ ១១ ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

**ចម្លងជូន៖**

-អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

" ដើម្បីជូនជ្រាបជាព័ត៌មាន"

-ឯកសារ កាលប្បវត្តិ នាយកដ្ឋានហិរញ្ញវត្ថុ